# ទិវាអន្តរជាតិស្តីពីជនជាតិដើមភាគតិចពិភពលោក

**៩ សីហា ២០០៩**

*សេចក្តីថ្លែងការណ៍របស់អ្នកស្រី ណាវី ភីឡៃ*
*ឧត្តមស្នងការ អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្ស*

ទិវាអន្តរជាតិស្តីពីជនជាតិដើមភាគតិចពិភពលោក ជាឱកាសមួយ ដើម្បីគូសបញ្ជាក់អំពីសារៈសំខាន់នៃសិទ្ធិជនជាតិដើមភាគតិច និងសំដែងនូវការស្ងើចសរសើរចំពោះតំលៃ និងភាពរឹងមាំនៃវប្បធម៌របស់ពួកគេ ។

ចាប់តាំងពីមហាសន្និបាតអង្គការសហប្រជាជាតិបានបង្កើតទិវាអន្តរជាតិនេះឡើង កាលពីប្រមាណជាដប់ប្រាំឆ្នាំមុខ យើងទទួលបានការរីកចំរើនយ៉ាងធំធេញក្នុងកិច្ចខិតខំប្រឹងប្រែងរួមរបស់យើង ដើម្បីលើកកំពស់សិទ្ធិជនជាតិដើមភាគតិច ។ សមិទ្ធិផលនេះ រាប់ទាំងការអនុម័តសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច ដែលជាការវិវត្តន៍ដ៏សំខាន់នៃបទដ្ឋានសិទ្ធិមនុស្ស និងការប្រកាសបើកអាណត្តិចំនួនបី សំរាប់សិទ្ធិជនជាតិដើមភាគតិច ។

ទោះជាយ៉ាងណាក៏ដោយ ការពិតដែលជនជាតិដើមភាគតិចតែងជួបប្រទះជារឿយៗនោះ គឺការស្ថិតនៅឆ្ងាយពីគោលការណ៍សិទ្ធិមនុស្សដែលមានចែងក្នុងសេចក្តីប្រកាសនេះ និងក្នុងសន្ធិ-សញ្ញាសិទ្ធិមនុស្សនានា ។

យើងទាំងអស់គ្នាត្រូវបង្កើនកិច្ចខិតខំប្រឹងប្រែង ដើម្បីបិទភ្ជិតចន្លោះប្រហោងនេះ និងធ្វើឲ្យសេចក្តីប្រកាសនេះក្លាយទៅជាអ្វីមួយដែលលើសពីការសន្យាអំពីបំណងប្រាថ្នាទៅទៀត ។ ទិវាអន្តរជាតិនាថ្ងៃនេះ គឺជាឱកាសដ៏អស្ចារ្យមួយ ដើម្បីអះអាងជាថ្មីអំពីការប្តេជ្ញាចិត្តរបស់យើង ដើម្បីប្រែក្លាយការវិវត្តន៍ជាវិជ្ជមាន ក្នុងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិទៅជាការរីកចំរើនពិតប្រាកដសំរាប់ជនជាតិដើមភាគតិច ។

ដើម្បីសំរេចកិច្ចការនេះ យើងទាំងអស់គ្នា (រដ្ឋ ជនជាតិដើមភាគតិច ប្រព័ន្ធសហប្រជាជាតិ និងស្ថាប័នឯទៀតដែលពាក់ព័ន្ធ) ត្រូវចូលរួមក្នុងកិច្ចខិតខំប្រឹងប្រែងរបស់យើង និងឈានដល់ការដោះស្រាយដែលផ្អែកលើការពិភាក្សាពិតប្រាកដ ការយោគយល់គ្នាទៅវិញទៅមក ភាពអត់ឱន និងការគោរពសិទ្ធិមនុស្ស ។ នេះមិនមែនជាការងាយស្រួលនោះទេ ។ ប៉ុន្តែវាជាវិធីតែមួយគត់ដែលយើងអាចធ្វើបាន ដើម្បីប្រែក្លាយសិទ្ធិរបស់ជនជាតិដើមភាគតិចពីអ្វីដែលមាននៅក្នុងក្រដាសឲ្យទៅជាការអនុវត្តន៍ជាក់ស្តែង ។

ការិយាល័យយើងខ្ញុំសន្យាថានឹងគាំទ្រដល់ការប្រកាន់ខ្ជាប់ និងការអនុវត្តន៍ជាសកលនៃសេចក្តីប្រកាស និងបន្តគាំទ្រដល់យន្តការសិទ្ធិមនុស្សទាក់ទងនឹងសិទ្ធិជនជាតិដើមភាគតិច ។

អង្គភាពព័ត៌មាននៃការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស
Palais Wilson
Tel: +41 22 917 9115